**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

28/5

**បណ្តឹងរដ្ឋប្បវេណី**
លេខ: ១១៩ ចុះថ្ងៃទី ០៩
ខែ មិថុនា ឆ្នាំ ២០១០
កាលបរិច្ឆេទបញ្ចប់ការទាញ
ហេតុផលដោយផ្ទាល់មាត់
ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១
**សាលក្រម**
លេខ: ០៥ (គ)
កាលបរិច្ឆេទប្រកាស
សាលក្រមថ្ងៃទ ០៤
ខែ មីនា ឆ្នាំ ២០១១

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តបន្ទាយមានជ័យ**

បានសម្រេចចេញសាលក្រមដែលមានគូភាគី:

- រវាងដើមចោទ:ឈ្មោះ [redacted] ចឹក ភេទ ប្រុស អាយុ ៩៣ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើស្រែ អាស័យដ្ឋានភូមិ ដងរុនកើត ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] គុជ (ស) ម្តាយឈ្មោះ [redacted] គៀន (ស) ប្រពន្ធឈ្មោះ [redacted] សុខុម (រ) មានកូន ០៥នាក់ ។

- និងចុងចម្លើយ:

១- ឈ្មោះ [redacted] លន់ ភេទ ស្រី អាយុ ៨៧ឆ្នាំ ជាតិ ខ្មែរ មុខរបរ លក់ដូរ អាស័យដ្ឋានភូមិ អូរស្វូត ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] គុជ (ស) ម្តាយឈ្មោះ [redacted] គៀន (ស) ប្តីឈ្មោះ [redacted] រិត (លែងលះ) មានកូនគ្មាន ។

២- ឈ្មោះ [redacted] លួម ភេទ ស្រី អាយុ ៨១ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើស្រែ អាស័យដ្ឋានភូមិ គោកក្លួច ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] គុជ (ស) ម្តាយឈ្មោះ [redacted] គៀន (ស) ប្តីឈ្មោះ [redacted] ភាន (រ) មានកូន ០៣នាក់។

៣- ឈ្មោះ [redacted] ធី ភេទ ប្រុស អាយុ ៣៧ឆ្នាំ ជាតិ ខ្មែរ មុខរបរ ជួសជុលម៉ូតូ អាស័យដ្ឋានភូមិ អូរស្វូត ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] គុជ (ស) ម្តាយឈ្មោះ [redacted] គៀន (ស) ប្រពន្ធឈ្មោះ [redacted] ឡាំជា (រ) មានកូន ០៤ នាក់ ។

## អង្គហេតុ និងចំណុចវិវាទ

ក- ខ្លឹមសារសាលក្រមដែលទាមទារដោយដើមចោទ

ដើមចោទប្តឹងសុំឲ្យតុលាការចេញសាលក្រមដូចតទៅ:

-សុំឲ្យបញ្ជាក់អំពីសិទ្ធិកាន់កាប់ និងសុំឲ្យចុងចម្លើយ ប្រគល់ដីដែលមានចំនួន០១រ៉ៃ បណ្តោយ៥០ម៉ែត្រ គុណនឹងទទឹង ៨០ម៉ែត្រ ស្ថិតនៅភូមិដងរុនលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់នឹងយាយ [redacted] និង [redacted] ទី ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ [redacted] សួរ និង ខាងលិចទល់នឹង នាង មួយ។

ខ- ខ្លឹមសារសាលក្រមដែលទាមទារដោយចុងចម្លើយ

-សុំទាមទារនូវមរតកដីចំការទំហំ ២៨៤០ម៉ែត្រការ៉េ ស្ថិតនៅភូមិ ដងរុនលិច ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្តបន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់នឹងយាយ [redacted] និង [redacted] ទី ខាងកើតទល់នឹងប្រ

១៩៤

ឡាយ ខាងត្បូងទល់នឹងឈ្មោះ [redacted] សួរ និង ខាងលិចទល់នឹង នាង មួយ ពីឈ្មោះ [redacted] ចឹក។

- ឲ្យរោយរចុងចម្លើយរក៏បរងលើប្រាក់ប្រអប់ក្តី ។

28/4

គ- ការពន្យល់រឿងក្តីត្រួសៗ

ក្រោយពីបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់ហត់រួចមក ឃើញថា:

ឈ្មោះ [redacted] គៀន ត្រូវជាម្តាយបង្កើតរបស់ភាគីមានដីចំការមួយកន្លែងទំហំជាងបួនរយ៉តីមំហ៊ ២៨២០ម៉ែត្រការ៉េ ស្ថិតនៅភូមិ ដងរុនលិច ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] វុន និង [redacted] ទី ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ ប៊ុន សួរ និងខាងលិចទល់នឹង [redacted] មួយ។ ដើមចោទឈ្មោះ [redacted] ចឹក បានរៀបការហើយបានបែកផ្ទះ ចំណែកចុងចម្លើយឈ្មោះ [redacted] លន់, ឈ្មោះ [redacted] លួម និងឈ្មោះ [redacted] ធី មិនទាន់បែក ហើយបានទៅមើលថែរក្សាម្តាយរហូតដល់ម្តាយទទួលមរណៈភាព។ ក្រោយពេលឈ្មោះ [redacted] គៀន បានទទួលមរណៈភាពទៅ បានបន្សល់ទុកនូវដីចំការមួយកន្លែងនេះ តែមិនបានបញ្ជាក់ថាចែកដីមួយកន្លែងនេះទៅឲ្យកូនម្នាក់ណាទេ គឺគ្រាន់តែបានផ្តាំឲ្យយកដីនេះទៅលក់សងបំណុលគេ ប៉ុណ្ណោះ។ ក្រោយមកចុងចម្លើយឈ្មោះ [redacted] លួម ជាកូនមិនបានយកដីនោះទៅលក់ទេ គឺបានទៅស៊ីឈ្នួលគេ យកលុយទៅលោះបំណុលគេ។ បន្ទាប់មកដើមចោទឈ្មោះ [redacted] ចឹក ជាបងរបស់ឈ្មោះ [redacted] លួម ក៏បានមកសុំខ្ចីដីចំការនោះ ដើម្បីទៅបង្កបង្កើនផលស្រូវ ដោយបានចែកផលឲ្យប្អូនឈ្មោះ [redacted] លួម ដែរ។ រហូតដល់រវាងឆ្នាំ ២០១០ ខាងស៊ុរីយោដីបានចុះទៅធ្វើប្លង់ដីឲ្យ ហើយដើមចោទបានហៅចុងចម្លើយឲ្យទៅធ្វើប្លង់ តែដល់ថ្ងៃធ្វើប្លង់ក៏ស្រាប់តែដើមចោទ មិនព្រមប្រគល់ដីឲ្យចុងចម្លើយ វិញទេ ។

ឃ- ចំណុចវិវាទ:

ដើមចោទអះអាងថាដីនោះជាដីកេរដែលម្តាយបានចែកឲ្យ ឯចុងចម្លើយទាំងបីបានអះអាងថាដីនោះជាដីរបស់ពួកខ្លួន ដែលមិនបានលក់សងបំណុលគេតាមបណ្តាំម្តាយ ដោយរកចំណូលផ្សេងមកលោះបំណុលឲ្យម្តាយ ដើម្បីរក្សាដីនោះទុក។

## សំអាងហេតុ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍ របស់ដើមចោទ និងបានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់ហត់ រួចមក យល់ឃើញថា:

- ដីចំការមួយកន្លែង ស្ថិតនៅភូមិ ដងរុនលិច ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្តបន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់នឹងយាយ [redacted] និង [redacted] ទី ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ [redacted] សួរ និង ខាងលិចទល់នឹង [redacted] មួយ ពិតជា កេរមរតករបស់ម្តាយដើមចោទ និងចុងចម្លើយ ដែលបានបន្សល់ទុកក្រោយពេលទទួលមរណៈភាព ពិតប្រាកដមែន។

- ដើមចោទឈ្មោះ [redacted] ចឹក បានអះអាងថា ដីចំការមួយកន្លែងចំនួន០១រ៉ៃ បណ្តោយ៤០ម៉ែត្រ គុណនឹងទទឹង ៤០ម៉ែត្រ ស្ថិតនៅភូមិ ដងរុនលិច ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់នឹងយាយ [redacted] និងតា ទី ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ [redacted] សួរ និង ខាងលិចទល់នឹង [redacted] មួយ ខ្លួនបានកាន់កាប់ និងប្រើប្រាស់ជាបួយម្តាយតាំងពីឆ្នាំ ១៩៧៩ ហើយ

១៩៥

ក្រោយពេលម្តាយស្លាប់បានប្រគល់ដីនោះមកឲ្យខ្លួន ពិតប្រាកដមែន តែមិនមានសាក្សី ឬភស្តុតាងអ្វីមកបញ្ជាក់ទេ។

- តាមចម្លើយសាក្សីរបស់ដើមចោទឈ្មោះ [redacted] ឆាត និងឈ្មោះ [redacted] យៀង បានបញ្ជាក់ថាពួកខ្លួនគ្រាន់តែបានឃើញឈ្មោះ [redacted] ចឹក បង្កបង្កើនផលលើដីចំការមួយកន្លែងតាំងពីឆ្នាំ ១៩៧៩មក តែការដែលពួកខ្លួនមកធ្វើជាសាក្សីឲ្យដើមចោទ គឺមិនបានដឹងថា ភាគីមានទំនាស់ជាមួយគ្នាពីរឿងដីទំហំប៉ុន្មានទេ ហើយក៏មិនបានដឹងថាឈ្មោះ [redacted] កៀន ស្លាប់ពេលណាទេ ។

- តាមចម្លើយសាក្សីទាំងពីរខាងលើបានបញ្ជាក់ថាពួកខ្លួនគ្រាន់តែបានឃើញដើមចោទឈ្មោះ [redacted] ចឹក ហ្នឹងទេ ដែលបានបង្កបង្កើនផលនៅលើដីចំការនេះមិនមានអ្នកផ្សេងទេ តែចម្លើយនេះហាក់ដូចជាមិនស្របគ្នាជាមួយចម្លើយរបស់ដើមចោទដែលបានអះអាងថាខ្លួន និងម្តាយបានបង្កបង្កើនផលលើដីចំការនេះ។

- ចុងចម្លើយទាំងបីនាក់បានអះអាងថា ដីចំការមួយកន្លែងទំហំ ២៨២០ម៉ែត្រការ៉េ ស្ថិតនៅភូមិ ដងរុនលិច ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់នឹង[redacted] រុន និង[redacted] ទី ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ [redacted] សួរ និង ខាងលិចទល់នឹង [redacted] មួយ ជាដីរបស់ម្តាយពួកខ្លួន ដែលបានទទួលពីឈ្មោះ [redacted] ទី ពីឆ្នាំ ១៩៨០ គាត់ក៏បានកាន់កាប់ដីនោះតែម្នាក់ឯងរហូតដល់ ឆ្នាំ ១៩៨៧ ម្តាយពួកខ្លួនក៏បានឈឺរ៉ាំរ៉ៃរស់រយៈពេលមួយឆ្នាំ ហើយបានឲ្យឈ្មោះ [redacted] លួម ទៅខ្ចីលុយគេដើម្បីមើលជម្ងឺគាត់សរុបចំនួន ចំនួនពីរម៉ឺនបាត ។

- ក្នុងអំឡុងដែលម្តាយមានជំងឺនោះ គឺចុងចម្លើយឈ្មោះ [redacted] លួម និងឈ្មោះ [redacted] ធី បានមើលថែទាំម្តាយ ហើយមុនពេលម្តាយស្លាប់បានផ្តាំថា ឲ្យយកដីនោះទៅលក់សងបំណុលគេ ចំនួនពីរម៉ឺនបាត។

- ក្រោយពេលម្តាយស្លាប់ហើយ ចុងចម្លើយឈ្មោះ [redacted] លួម បានទៅស៊ីឈ្នួលគេដើម្បីសងបំណុលដែលម្តាយខ្លួនបានជំពាក់គេ ដោយមិនបានយកដីចំការនេះទៅលក់ទេ ក្រោយមកដើមចោទឈ្មោះ [redacted] ចឹក បានមកខ្ចីដីចំការនេះដើម្បីបង្កបង្កើនផល ហើយខ្លួនបានបញ្ជាក់ច្បាស់ថាដីចំការនេះជារបស់ខ្លួន ហើយដើមចោទក៏បានអះអាងថា បើខ្លួនចង់បានដីវិញពេលណាក៏បាន តែនៅឆ្នាំ ២០១០ ខាងសុរិយោដីបានចុះទៅធ្វើប្លង់ដីឲ្យ ហើយដើមចោទបានហៅខ្លួនឲ្យទៅធ្វើប្លង់ តែដល់ថ្ងៃធ្វើប្លង់ក៏ស្រាប់តែដើមចោទ មិនព្រមប្រគល់ដីឲ្យខ្លួនវិញទេ ។

- តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ទី បញ្ជាក់ថា ខ្លួនត្រូវជាអ្នកជិតខាង។ មុនសម័យប៉ុលពត គឺដីរបស់ឈ្មោះ កៀន ហើយខ្លួនបានកាន់កាប់ដីនោះ នៅឆ្នាំ ១៩៧៩ ខ្លួនបានប្រគល់ដីនោះឲ្យទៅម្ចាស់គេវិញគឺ ឈ្មោះ ថៃកៀន។ ខ្លួនមិនបានដឹងពីទំហំដីនោះទេ។ ខ្លួនមិនដែលឃើញឈ្មោះ [redacted] ចឹក ទៅបង្កបង្កើនផលលើដីនោះទេ។

- តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សុខុម បញ្ជាក់ថា ខ្លួនជាជន្លងជាប្អូនឪពុកក្មេករបស់ភាគី ហើយបានអះអាងថាខ្លួនបានដឹងថាដីនោះ ជាដីរបស់ជន្លងខ្លួន ហើយខ្លួនបានឃើញចុងចម្លើយទាំងបីនាក់បានរស់នៅជាមួយម្តាយហើយបានបង្កបង្កើនផលលើដីចំការទំហំជាងមួយរ៉ៃ ស្ថិតនៅភូមិ ដងរុនលិច ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ ហើយនៅពេលម្តាយឈឺចុងចម្លើយក៏បាននាំគ្នាមើលថែរក្សាម្តាយរហូតដល់ម្តាយស្លាប់ ក៏ឃើញឈ្មោះ គុជ ចឹក បង្កបង្កើនផលលើដីនោះវិញ តែមិនបានដឹងមូលហេតុអ្វីទេ។

- តាមចម្លើយរបស់សាក្សីឈ្មោះ ស៊ឹម អែម បញ្ជាក់ថា ខ្លួនជាត្រូវជា បងបង្កើតរបស់ភាគី។ ដីចំការទំហំ ជាងមួយរ៉ៃ ស្ថិតនៅភូមិ ដងរុនលិច ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ នោះគឺជា

ដីកេររបស់ហ្គាយខ្លួនតាំងពីសង្គម។ ពេលបានដីនោះមកហ្គាយខ្លួនមិនបានបែងចែកដីនោះទេ គឺកូនចៅដែលបានគ្រួសារបានចំណែករាងខ្លួនហើយ គឺខ្លួន និងឈ្មោះ [redacted] ចឹក បានគ្រួសារ ចេញហើយ ហើយនៅតែឈ្មោះ [redacted] ធី, [redacted] លួម និងឈ្មោះ [redacted] លន់ នៅក្នុងបន្ទុកមិនទាន់បានចំណែកទេ។ ពេលហ្គាយខ្លួនឈឺនោះ [redacted] ធី និង [redacted] លួម បានមើលថែទាំគាត់ រួមទាំងខ្លួនដែរ ហើយបានដឹងថាហ្គាយខ្លួន ឲ្យឈ្មោះ [redacted] លួម ខ្ចីលុយគេចំនួន ពីរម៉ឺនបាត ពីឈ្មោះ [redacted] និងឈ្មោះ កុយ ហើយមុនពេលហ្គាយស្លាប់ខ្លួនបានដឹងនិងលឺផ្ទាល់ថាហ្គាយខ្លួនបានផ្តាំឲ្យលក់ដីនោះសងគេ តែប្អូនខ្លួនមិនបានលក់ដីនោះទេ ដោយវាបានទៅស៊ីឈ្នួលគេដោះបំណុល។ បន្ទាប់មកឈ្មោះ [redacted] ចឹក បានខ្ចីដីនោះទៅបង្កបង្កើនផល ហើយបានចែកផលមកឲ្យប្អូនៗដែរ តែបីឆ្នាំក្រោយមិនបានចែកទេ។ ខ្លួន និងឈ្មោះ [redacted] ចឹក បានចំណែករួចហើយពេលរៀបការមានគ្រួសារ នៅតែចុងចម្លើយបីនាក់នេះទេដែលនៅក្នុងបន្ទុកមិនទាន់បានទទួលចំណែក។

- តាមចម្លើយសាក្សីរបស់ចុងចម្លើយទាំងរស់បានបញ្ជាក់ថា ដីចំការមួយកន្លែងទំហំ ជាង០១ហ៊ិ ស្ថិតនៅភូមិ ដងរុនលិច ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់នឹងយាយ វុន និងគ្រូ ទី ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ [redacted] សូវ និង ខាងលិចទល់នឹង នាង មួយ គឺជាដីដែលចុងចម្លើយទាំងបីនាក់បានថែរក្សា និងបង្កបង្កើនផលជាមួយហ្គាយរហូតដល់ហ្គាយស្លាប់មែន។

- តាមចម្លើយសាក្សីរបស់ចុងចម្លើយបានបញ្ជាក់ថាហ្គាយរបស់ចុងចម្លើយ ពិតជាបានជំពាក់លុយគេ ហើយបានផ្តាំថាឲ្យចុងចម្លើយលក់ដីចំការនោះសងបំណុលគេ ដោយមិនបានចែកដីនោះឲ្យទៅកូនណាម្នាក់ទេ ពិតប្រាកដមែន។

- តាមចម្លើយសាក្សីរបស់ចុងចម្លើយ ឃើញថាចុងចម្លើយឈ្មោះ [redacted] លួម ពិតជាបានទៅស៊ីឈ្នួលគេដើម្បីដោះបំណុលហ្គាយ ដោយគោលបំណងទុកដីចំការមួយកន្លែងនេះសម្រាប់បង្កបង្កើនផលចិញ្ចឹមជីវិតពិតប្រាកដមែន។

- យោងតាមលិខិតបញ្ជាក់ចុះថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១០ ដែលមានចុះហត្ថលេខារបស់ភូមិ ឃុំ និងស្រុក បានបញ្ជាក់ថាដីចំការមួយកន្លែង ស្ថិតនៅភូមិ ដងរុនលិច ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់នឹង [redacted] វុន និង [redacted] ទី ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ [redacted] សូវ និង ខាងលិចទល់នឹង [redacted] មួយ គឺមានទំហំ ២៨២០ម៉ែត្រការ៉េ ដូចចុងចម្លើយទាំងបីបានលើកឡើង ពិតប្រាកដមែន។

- ចុងចម្លើយទាំងបីបានសំណូមពរទាមទារយកដីចំការមួយកន្លែងទំហំ ២៨២០ម៉ែត្រការ៉េ ស្ថិតនៅភូមិ ដងរុនលិច ឃុំ បន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់នឹង [redacted] វុន និង [redacted] ទី ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ [redacted] សូវ និង ខាងលិចទល់នឹង នាង មួយនេះមកគ្រប់គ្រង ដើម្បីបែងចែកជាបីចំណែកស្មើគ្នា តុលាការនឹងពិចារណា។

## សេចក្តីសម្រេចបញ្ចប់

១- ច្រានចោល ពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ គុជ ចឹក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០។

២- ទទួលស្គាល់ ពាក្យបណ្តឹងតបរបស់ចុងចម្លើយឈ្មោះ [redacted] លន់, ឈ្មោះ [redacted] លួម និងឈ្មោះ [redacted] ធី ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០។

១៩៧

28/1

៣- ប្រគល់សិទ្ធកាន់កាប់ដីចំការមួយកន្លែងទំហំ ២៨២០ម៉ែត្រការ៉េ ស្ថិតនៅភូមិ ដងរុនលិច ឃុំបន្ទាយនាង ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់នឹង [redacted] វុន និ[redacted] ទូ ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ [redacted] សួរ និង ខាងលិចទល់នឹង [redacted] មួយ ឲ្យទៅចុងចម្លើយឈ្មោ[redacted] លន់ ~~ភេទ ស្រី, ឈ្មោះ~~ [redacted] លួម ភេទ ស្រី និងឈ្មោះ [redacted] ធី ភេទ ប្រុស ដើម្បីបែងចែកជាបីចំណែកស្មើគ្នា។

៤- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចុងចម្លើយ បើភាគីណាមិនសុខចិត្តមានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ចៅក្រមជំនុំជំរះ

[redacted]